# លទ្ធផលសង្ខេបនាពីរកចំរីនរបស់សហពន្ធ័ក្រុមផលិតស្រូវសរីរាង្គ ឆ្នាំ ២០០៨

អង្គការសេដាកបានផ្តួចផ្តើមគំនិតរៀបចំនូវក្រុមផលិតស្រូវសរីរាង្គចាប់តាំងពីឆ្នាំ ២០០៤ ដើម្បីភ្ជាប់កសិករមកទីផ្សារ ។ គោលបំណងសំខាន់ក្នុងការរៀបចំក្រុមផលិតស្រូវសរីរាង្គនេះដើម្បី និងជួយដល់កសិករក្នុងការលក់ស្រូវបានតម្លៃសមរម្យ ក៏ដូចជាការពង្រឹងការសហការ និងអំណាចរបស់សហគមន៍ក្នុងការលក់ស្រូវមកទីផ្សារ ។

របាយការណ៏នេះនឹងធ្វើការសង្ខេបនូវលទ្ធផលសំខាន់ៗ របស់សេដាកក្នុងការសំរបសំរួលបង្កើតក្រុមផលិតស្រូវសរីរាង្គរហូតមកដល់ឆ្នាំ ២០០៨ ដូចខាងក្រោមៈ

## ១. លទ្ធផលសំរេចបាន ២០០៨

| ល.រ | ការពិពណ៌នា | ២០០៤/<br>២០០៥ | ២០០៥/<br>២០០៦ | ២០០៦/<br>២០០៧ | ២០០៧/<br>២០០៨ | ២០០៨/<br>២០០៩ |
|---|---|---|---|---|---|---|
| ១ | ចំនួនខេត្តគោលដៅ | ៣ | ៣ | ៥ | ៨ | ៨ |
| ២ | ចំនួនស្រុក | ៥ | ៧ | ១០ | ២៨ | ៣៦ |
| ៣ | ចំនួនក្រុម/ភូមិ | ១១៤ | ២២៨ | ៣៦០ | ៤៣៤ | ៧៧២ |
| ៤ | ចំនួនសមាជិកក្រុម (នាក់) | ២០៩៧ | ២០០៤ | ៣០០១ | ៣៦០៤ | ៨០១០ |
| ៥ | បរិមាណស្រូវសរីរាង្គបានលក់មកទីផ្សារ(តោន) | ១០ | ១២៥ | ៤៨០ | ១២០០ | ៤០០០ |
| ៦ | បរិមាណទឹកប្រាក់បង្វិលទៅសហគមន៍ (លានរៀល) | | ៣.៧៥ | ២៤ | ១២០ | - |

- ខេត្តគោលដៅរបស់ក្រុមផលិតស្រូវសរីរាង្គមានៈ តាកែវ កំពង់ស្ពឺ កំពង់ឆ្នាំង កំពង់ធំ កំពង់ចាម កំពត ព្រៃវែង និងស្វាយរៀង ។

## ២. យុទ្ធសាស្ត្រក្រុមសរីរាង្គទៅខាងមុខ

ចាប់ពីពេលនេះ រហូតដល់ឆ្នាំ ២០១០ សហពន្ធ័ក្រុមផលិតស្រូវសរីរាង្គ គ្រោងសំរេចដូចខាងក្រោមៈ

- ចំនួនក្រុមផលិតនឹងកើនដល់ ១៣០០ ក្រុម ដែលមានសមាជិកចំនួន ១៣០០០ នាក់ ធ្វើនៅខេត្តគោលដៅចំនួន ១០ ។ បរិមាណស្រូវចំនួន ៨០០០ តោន នឹងត្រូវទិញពីសហគមន៍ ។
- ធ្វើការពង្រឹងដល់សហគមន៍ និងសហពន្ធ័ក្រុមផលិតស្រូវសរីរាង្គតាមតំបន់ អោយមានលក្ខណៈស្វ័យគ្រប់គ្រងដោយខ្លួនឯង ដើម្បីក្លាយជាដៃគូរយ៉ាងសំខាន់របស់ទីផ្សារសេដាក និងដៃគូរទំនួញផ្សេងៗ ។
- ធ្វើការពង្រីកទីផ្សារស្រូវសរីរាង្គអោយបានគ្រប់ខេត្តក្រុងទាំងអស់នៅក្នុងប្រទេស ជាពិសេសតាមរយៈការពង្រីកពូជស្រូវ ដែលជាតំរូវការនៅក្នុងខេត្ត និងចាប់យកដៃគូរលក់អោយបានច្រើន ។
- ពិនិត្យមើលលទ្ធភាព ដើម្បីបង្កើនធ្វើការនាំចេញទៅក្រៅប្រទេស ។